

ម៉េង សាអ៊ីន ទទួលបានព្រះគម្ពីរបរិសុទ្ធ១ក្បាល។ រូបថត លោកគ្រូ ពៅ សំណាង ភ្នំពេញ
Mang Sa-in received The Holy Bible Khmer version. Photo: Pastor Peou Samnang, Phnom Penh.

# ពីសេចក្ដីអស់សង្ឃឹម មកជាសេចក្ដីជំនឿលើព្រះពិត

អ្នកស្រី ម៉េង សាអ៊ីន ជាស្ត្រីមេម៉ាយ ដែលមានកូនពីរនាក់ និងចិញ្ចឹមម្ដាយចាស់ជរាម្នាក់ទៀតក្នុងបន្ទុក។ ប្ដីរបស់អ្នកស្រីបានស្លាប់ចោលអ្នកស្រីដោយជំងឺរាគាពាធ។ អ្នកស្រី ម៉េង សាអ៊ីន កាលពីមុនទទួលជឿព្រះយេស៊ូវគ្រីស្ទ អ្នកស្រីក៏ដូចជាអ្នកដទៃទៀត ដែលគោរពជឿប្រតិបត្តិតាមសាសនា ក៏ប៉ុន្តែពុំមានឃើញអ្វី ដែលមកបញ្ជាក់ប្រាប់អះអាងពីសេចក្ដីជំនឿឲ្យបានពិតប្រាកដ ដូចដែលអ្នកស្រីបានទទួលយកព្រះអម្ចាស់យេស៊ូវគ្រីស្ទ ធ្វើជាព្រះអម្ចាស់ ទើបអ្នកស្រីដឹងថា អ្វីទៅដែលជាសេចក្ដីពិត ក្នុងជីវិតរស់នៅ។ ព្រោះថា តាមរយៈព្រះបន្ទូលរបស់ព្រះអាទិករ មានចែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ តែងតែបង្ហាត់បង្រៀនអ្នក

ស្រីពីសេចក្ដីពិតរបស់ព្រះអម្ចាស់ ដ្បិតព្រះអង្គទ្រង់ជាព្រះដ៏ជួយសង្គ្រោះ ហើយនិងប្រទានមកអ្នកស្រីនូវសេចក្ដីសង្ឃឹមជារៀងរាល់ថ្ងៃ។

ការនេះធ្វើឲ្យអ្នកស្រីបាននឹកឃើញពីដំណើរ នៃការចាប់ផ្ដើមសេចក្ដីជំនឿរបស់អ្នកស្រីលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺតាមរយៈលោកគ្រូគង្វាលម្នាក់ ដែលបានមកផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ដោយមានទាំងនាំយកកូនសៀវភៅពីរក្បាលមកឲ្យដល់អ្នកស្រី នោះគឺកូនសៀវភៅ □ស្ពានជីវិត□ និង □តើព្រះជានរណា?□ ទុកសម្រាប់អ្នកស្រីអាននិងរៀនសូត្រ។ ក្រោយមកទៀត អ្នកស្រីក៏បានសម្រេចចិត្តទទួលយកព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ធ្វើជាព្រះអម្ចាស់នៃជីវិតរបស់អ្នកស្រី ដោយសារតែអ្នកស្រីចង់ដឹង និងយល់ឲ្យបានកាន់តែច្បាស់ទៅទៀតអំពីសេចក្ដីពិតក្នុងជីវិត។ អ្នកស្រីក៏ទទួលបានព្រះគម្ពីរបរិសុទ្ធមួយក្បាលជាបន្ថែមទៀត ដើម្បីសម្រាប់អ្នកស្រីអានព្រះបន្ទូលព្រះជារៀងរាល់ថ្ងៃ។ ព្រោះថាព្រះបន្ទូលទ្រង់ បង្ហាញពីសេចក្ដីពិតនៃជីវិត ដូចដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់បានមានព្រះបន្ទូលថា៖ □*ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ*□។ ក្រោយបន្ទាប់មកទៀត អ្នកម្ដាយរបស់អ្នកស្រីក៏សម្រេចទទួលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយទទួលយកព្រះអង្គទ្រង់ធ្វើជាព្រះអង្គសង្គ្រោះរបស់គាត់ក្នុងជីវិត។ ម៉្យាងវិញទៀត កាលណាយើងរាល់គ្នាបានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អពីសេចក្ដីសង្គ្រោះរបស់យើង ហើយកាលណាយើងរាល់គ្នាបានទទួលជឿទ្រង់ នោះព្រះអង្គទ្រង់ក៏ដៅចំណាំយើងរាល់គ្នាដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យាផងដែរ។ អ្នកស្រីក៏បានបញ្ជាក់ពីដួងចិត្តរបស់អ្នកស្រីថា៖ □ខ្ញុំសូមប្ដេជ្ញាចិត្ត ដើរតាមនិងស្ដាប់បង្គាប់ព្រះអម្ចាស់ ហើយនិងនាំយកដំណឹងល្អពីសេចក្ដីពិតនេះទៅប្រាប់ដល់អ្នកដទៃទៀត ដើម្បីឲ្យពួកគេទទួលបានសេចក្ដីសង្គ្រោះដូចជាក្រុមគ្រួសាររបស់នាងខ្ញុំដែរ□។ នៅពេលដែលអ្នកស្រី មានទុក្ខលំបាក អ្នកស្រីក៏បានចំណាយពេលវេលាជាមួយនឹងទ្រង់ អធិស្ឋានទូលថ្វាយអស់សព្វគ្រប់ទាំងការដល់ព្រះអង្គទ្រង់ ហើយនិងអានព្រះបន្ទូលនៃសេចក្ដីពិតជាប់ជាប្រចាំជារៀងរាល់ថ្ងៃ ព្រមទាំងបានច្រៀងសរសើរតម្កើងដល់ព្រះសិរីល្អនៃទ្រង់ ដែលនាំជីវិតរបស់អ្នកស្រីទទួលបានសេចក្ដីសុខសាន្តយ៉ាងពិតប្រាកដ ដូចដែលបទ

គម្ពីរមានចែងប្រាប់នៅក្នុង អេភេសូរ ៤:១៥ ថា៖ □តែដោយកាន់តាមសេចក្តីពិត ដោយសេចក្តីស្រឡាញ់វិញ នោះឲ្យយើងបានធំឡើង ខាងឯគ្រប់ការទាំងអស់ក្នុងទ្រង់ ដែលទ្រង់ជាសិរសា គឺជាព្រះគ្រីស្ទ□។ អាម៉ែន។

## *From Despair Becomes the Faith in the True God*

Meng Sa In is a widow with two children and one elderly mother in charge. Her husband died by his sickness. Meng Saitin before believed in Jesus Christ, as well as others who respected and practiced the religion, but did not see anything confirming the truth as she had accepted the Lord Jesus Christ as her Lord, so right now she knew what was the truth in her life. Because through the inspired Word of God in the Bible, it teaches her the truth of the Lord, for He is the God of salvation and gives her hope every day.

This reminded her of the process of starting her faith in the Lord Jesus Christ, through a pastor who came to preach the gospel of Jesus Christ, bringing two booklets to her, a booklet is "Bridge of Life" and another is "Who Is God?" for her to read and study. Later, she decided to accept the Lord Jesus Christ as her Lord for her life because she wanted to know more and understand the truth in life. She also received a copy of the Bible in Khmer so that she could read the Word of God every day. Because His Word shows the truth of life, as the Lord Jesus Christ said, "*I am the way, the truth, and the life: no one comes to the Father, except through me.*" Later, her mother also decided to accept the Lord Jesus Christ, as her Savior in the life. On the other hand, when we hear the Word of truth, that is the Gospel of our salvation, and when we believe in Him, then He sealed us with the promised Holy Spirit. She also affirmed her heart: "I commit myself to follow and obey the Lord and bring this Gospel of truth to others so that they may be saved, as is my family." When she was in trouble, she spent time with Him, praying to God, and reading the Word of truth daily, and singing to glorify God, which brought her life in peace exactly as the scripture says in Ephesians 4:15: "*Rather, speaking the truth in love, we are to grow up in every way into him who is the head, into Christ,*" Amen.







# ពីអ្នកនេសាទត្រី មកជាអ្នកនេសាទមនុស្ស

លោក ជា ជឹន អាយុ ៤៥ឆ្នាំ ជាអ្នកនេសាទរស់នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ធ្លាប់កាន់តាមសាសនាដែរ ហើយនិងបន់ស្រន់ដល់អារក្សអ្នកតា ដើម្បីសូមឲ្យមានជីវភាពរស់នៅបានរួចពីសភាពក្រីក្រលំបាកតោកយ៉ាក ខ្វះមុខខ្វះក្រោយ តែពុំឃើញមានអ្នកណាឬអ្វីមួយមកជួយឲ្យជីវភាពរស់នៅរបស់គាត់ បានធូរធារឡើយ កាន់តែយ៉ាប់ទៅៗ។

មានថ្ងៃមួយលោក ជា ជឹន បានជួបនឹងលោកគ្រូផ្សាយដំណឹងល្អអំពីព្រះយេស៊ូវ នាពេលនោះឯងលោកគ្រូម្នាក់នោះក៏បាននិយាយទាក់ទងសួរនាំខ្ញុំ ទាំងទឹកមុខញញឹម ក្រោយពីការពន្យល់ប្រាប់លោក ជា ជឹន អំពីសេចក្តីសង្គ្រោះឲ្យរួចពីបាប ដែលកើតមានឡើងដោយព្រះយេស៊ូវ ដែលជាព្រះរាជបុត្រានៃព្រះ បានយាងមកចាប់បដិសន្ធិនឹងនាងក្រមុំព្រហ្មចារីយ៍ យោងយកកំណើតជាមនុស្ស ដើម្បីរងទុក្ខលំបាក និងសុគតលើឆ្កាងជំនួសអំពើបាបរបស់មនុស្សយើង ហើយនិង ៣ថ្ងៃ ក្រោយមកព្រះអង្គទ្រង់បានមានព្រះជន្មរស់ឡើងវិញ។ ដូច្នេះអស់អ្នកណា ដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នឹងទទួលបានសេចក្តីសង្គ្រោះឲ្យរួចពីបាប និងលែងមានសេចក្តីទុក្ខលំបាកណាមកគាបសង្កត់ទៀតហើយ។ ជាបន្ទាប់មក គាត់ក៏បានជូនកូនសៀវភៅពីរក្បាលទៅលោក ជា ជឹន គឺកូនសៀវភៅ □ស្ពានជីវិត□ និង □តើព្រះជានរណា?□ ដើម្បីរៀនសូត្រជាបន្តទៀត។ ជាចុងក្រោយលោកគ្រូម្នាក់នោះ បានផ្តាំផ្ញើទៅលោក ជា ជឹន ថា៖ □បើនៅពេលណាបងប្រុសសម្រេចចិត្តជឿលើព្រះយេស៊ូវ សូមបងប្រុសគ្រាន់តែអធិស្ឋានទូលសូមឲ្យព្រះអង្គទទួលយកបងប្រុសធ្វើជាកូនរបស់ព្រះទៅ ដោយទូល

សូមឲ្យព្រះអង្គអត់ទោសបាបដល់បងប្រុស នោះព្រះអង្គនឹងអត់ទោសដល់បងប្រុស ហើយនិងប្រទានពរដល់បងប្រុស ទៅតាមអ្វីដែលបងប្រុសចង់បាន។

មានថ្ងៃមួយ បងប្រុស ជា ជឹន ចេញដំណើរទៅប្រកបមុខរបររកស៊ីរបស់ខ្លួន ដោយការនេសាទត្រីរបស់ខ្លួនដូចសព្វដង។ តែនៅថ្ងៃនោះ គាត់ទម្លាក់អួនចុះទៅក្នុងទឹក រកចាប់ត្រីមិនបានមួយសោះ ស្រាប់តែគាត់នឹកឃើញពីពាក្យសម្ដីរបស់លោកគ្រូផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ប្រាប់គាត់ បើគាត់ត្រូវការឲ្យព្រះយេស៊ូវជួយ នោះចូរអធិស្ឋានទូលថ្វាយព្រះអង្គទ្រង់ សូមឲ្យព្រះអង្គទ្រង់បានអត់ទោសបាប ហើយព្រះអង្គទ្រង់នឹងប្រទានពរទៅតាមការចង់បាន។ គ្រាន់តែនឹកឃើញដូច្នោះ បងប្រុស ជា ជឹន មិនបានបង្អង់យូរទេ គាត់បានលុតជង្គង់ចុះដល់ដី ទាំងក្រាបមុខទៅដី ហើយលើកដៃប្រណមឡើង ទាំងអធិស្ឋានថា ឱព្រះអម្ចាស់យេស៊ូវអើយ សូមព្រះអង្គអត់ទោសបាបដល់ទូលបង្គំផង ព្រោះទូលបង្គំជាមនុស្សមានបាប ហើយសូមព្រះអង្គទទួលយកទូលបង្គំធ្វើជាកូនរបស់ព្រះអង្គទ្រង់ផង នៅថ្ងៃនេះទូលបង្គំរកចាប់ត្រីមិនបានសោះឡើយ។ រំពេចភ្លាមនោះដូចជាមានសម្លេងមួយលាន់ក្នុងត្រចៀកប្រាប់បងប្រុស ជា ជឹន ថា ទម្លាក់អួនម្តងទៀត បានត្រីហើយ! ។ ពេលនោះបងប្រុស ជា ជឹន ក៏ចាប់ផ្តើមធ្វើតាមសម្លេងប្រាប់នោះ ស្រាប់តែគាត់ហាក់បីដូចភ្ញាក់ព្រើតម្តងនេះអួនដូចជាមានទម្ងន់ខុសពីធម្មតា នៅពេលគាត់លើកឡើងស្រាប់តែឃើញសុទ្ធត្រីនៅពេញក្នុងអួន អស្ចារ្យណាស់ ព្រះយេស៊ូវ អស្ចារ្យណាស់ ការអស្ចារ្យកើតមានឡើង តាមការអធិស្ឋានមែន!។

លុះព្រឹកឡើង ខ្ញុំក៏បានទូរស័ព្ទសួររកលោកគ្រូផ្សាយដំណឹងល្អនោះ ហើយក៏ណាត់ជួបនឹងគាត់ ដើម្បីសុំឲ្យគាត់អធិស្ឋានឲ្យខ្ញុំ ដោយខ្ញុំបានផ្លាស់ប្រែចិត្តទទួលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ ពីព្រោះដោយបានឃើញការអស្ចារ្យ ដែលព្រះអម្ចាស់ទ្រង់បានធ្វើការអស្ចារ្យដល់រូបគាត់។ ក្រោយពេលដែលលោកគ្រូផ្សាយដំណឹងល្អនោះ បានអធិស្ឋានឲ្យខ្ញុំរួចហើយគាត់ក៏ផ្តាំផ្ញើពាក្យថា កុំភ្លេចមកថ្វាយបង្គំព្រះនៅព្រឹកថ្ងៃអាទិត្យនៅព្រះវិហារជាមួយនឹងគេ។ រួចមកបងប្រុស ជា ជឹន ក៏បានធ្វើដំណើរត្រឡប់ទៅផ្ទះ ព្រមទាំងទទួលបានព្រះគម្ពីរបរិសុទ្ធមួយក្បាលកាន់នៅក្នុងដៃទៅជាមួយផង។ ក្រោយពេលបាយល្ងាចរួច បងប្រុសបានចាប់ផ្តើមបើកព្រះគម្ពីរអាន តើមានអ្វីចម្លែក ដែលគួរឲ្យគាត់ចេះតែចង់ដឹងដូច្នោះ។ នាពេលនោះ

គាត់ក៏បើកព្រះគម្ពីរប៉ះចំកណ្ដាលគម្ពីរម៉ាថាយ ជំពូក ៤ រួចគាត់ក៏អាន ដែលនៅត្រង់នោះនិយាយរៀបរាប់អំពីព្រះយេស៊ូវជួបនឹងសេចក្ដីល្បួង ហើយគាត់ក៏បន្តអាន ដោយចេះតែចង់ដឹងរហូតដល់កថាខណ្ឌ ព្រះយេស៊ូវត្រាស់ហៅពួកសាវកជាលើកដំបូង នៅត្រង់ ខ.១៩ ព្រះយេស៊ូវមានបន្ទូលទៅ ស៊ីម៉ូន ដែលក្រោយមកហៅថា ពេត្រុស និងអនទ្រេ ជាប្អូនប្រុសថា៖ □*ចូរមកតាមខ្ញុំៗនឹងតាំងអ្នក ឲ្យជាអ្នកនេសាទមនុស្សវិញ*□។ បងប្រុស ជា ជីន ក៏ចាប់ផ្ដើមអធិស្ឋានទូលអរព្រះគុណដល់ព្រះអម្ចាស់ ដែលបានត្រាស់ហៅគាត់ ដោយចំៗតែម្ដងឲ្យចូលទៅបម្រើការងារផ្សាយដំណឹងល្អអំពីព្រះអម្ចាស់ ដើម្បីនាំដំណឹងល្អរបស់ទ្រង់ទៅដល់អស់ទាំងមនុស្ស ដែលបាត់បង់ទាំងឡាយ។

ក្រោយមកទៀត បងប្រុស ជា ជីន ក៏បានផ្សាយដំណឹងល្អអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅដល់ម្ដាយ ឪពុក របស់គាត់ ដើម្បីឲ្យពួកគាត់ទទួលបានសេចក្ដីសង្គ្រោះដូចជារូបគាត់ដែរ ហើយនិងដល់ប្រពន្ធកូនរបស់គាត់ទាំងអស់គ្នាផងដែរ។

ចាប់ពីពេលនោះមក បងប្រុស ជា ជីន ត្រូវបានព្រះបន្ទូលកម្សាន្តចិត្តគាត់ជារៀងរាល់ថ្ងៃតាមរយៈការអានព្រះគម្ពីររបស់គាត់ ជាពិសេសនៅត្រង់បទគម្ពីរ ម៉ាថាយ ៥:៣-១២ ថា៖ □[៣]មានពរហើយ អស់អ្នកដែលមានសេចក្ដីកំសត់ខាងឯវិញ្ញាណ ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ [៤]មានពរហើយ អស់អ្នកដែលយំសោក ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីកំសាន្តចិត្ត [៥]មានពរហើយ អស់អ្នកដែលស្លូតត្រង់ ដ្បិតអ្នកទាំងនោះនឹងគ្រងផែនដីជាមរដក [៦]មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្ដីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត [៧]មានពរហើយ អស់អ្នកដែលមានចិត្តមេត្តាករុណា ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីមេត្តាករុណាវិញ [៨]មានពរហើយ អស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ [៩]មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅជាកូនរបស់ព្រះ [១០]មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្ដីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ [១១]អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្ដីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ [១២]ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា បែបដូច្នោះដែរ។□។ អាម៉ែន។






# *From Fisherman To Fisher Of Men*

Chea Chen, a 45-year-old fisherman living in Prasat Sambo district, Kampong Thom province, has been praying to the idolatry and his ancestor spirits for his family's survival, getting from poverty and suffering, but he has not seen anyone or anything to help his living conditions, instead it becomes worse and worse.

One day, Mr. Chea Chen met a teacher who is an evangelist preaching about Jesus at that time the teacher had communicated with him with a smile. After his explanation to Chen about salvation from sin that comes from Jesus, the Son of God came to be born with a virgin to suffer and die on the cross instead of our sins, and 3 days later, He rose again from the dead. So, anyone who believes Jesus Christ will be saved and no longer suffering and any kind of trial. Then, that evangelist gave two booklets to Chen for reading and learning that booklets are "Bridge of Life Bridge" and “Who Is God?” Finally, the teacher told Chen: "Whenever you have decided to believe in Jesus, just pray to Him for accepting you as a son of God, asking Him to forgive the sin of you, so He will forgive you, and bless you, brother, and whatever you want."

One day, Chen went out to do his business with his fishing trout. But on that day, he dropped the nets into the water and had no fish to catch, and he remembered the words of the evangelist who told him about Good News of Jesus Christ, if he needs Jesus Christ to help him. Please pray to Him for His forgiveness, and He would bless you as you wish. Just remember that, brother Chen has not slowed down. He bowed his knees down to the ground, fell on his face, and held up his hands with prayer, saying, "Lord Jesus, forgive me of my sin, for I am a sinful man, and accept me as your son. Today I cannot catch anything, Lord. Suddenly, like a noise in his ears told brother Chen, "Drop your nets into the water again you will get fish!" Then, brother Chen started to follow the sound, and suddenly he seemed to be so surprised, as it was unusually weighed when he lifted up, and he saw full of fish in the net. Amazing! Jesus was amazing, wonderful from the prayer!

The next morning, I called for the evangelist and made an appointment to ask him to pray for me because I had converted to the Lord Jesus Christ because of the miracle that the Lord had performed for him. After the evangelist prayed for me, he reminded me that I did not forget to come to worship God on Sunday morning at the church with other people. Then, brother Chen went back home and got a Bible in his hand. After the dinner, the brother began to open the Bible to read. It was strange that he wanted to know it. At the time he opened the Bible, falling to the book of Matthew, chapter 4, he read that right there tells about Jesus to be tempted, and he continued to read paragraph with bold curiosity until Jesus called His first apostles at verse 19, Jesus said to Simon, later called Peter, and Andrew his brother, saying: 'Come, follow me, and I will make you fishers of men. Brother Chen began to pray for the Lord, who had called him directly to enter the evangelistic work of the Lord to bring His Gospel to all the lost people.

Later, Chen also preached the Gospel of the Lord Jesus Christ to his mother and father, in order for them to be saved as well as to his wife and children.

From that time, Chen was comforted of his daily life by reading the Bible,
especially in Matthew 5: 3-12: “3“Blessed are the poor in spirit, for theirs is the
kingdom of heaven. 4“Blessed are those who mourn, for they shall be comforted.
5“Blessed are the meek, for they shall inherit the earth. 6“Blessed are those who
hunger and thirst for righteousness, for they shall be satisfied. 7“Blessed are the
merciful, for they shall receive mercy. 8“Blessed are the pure in heart, for they shall
see God. 9“Blessed are the peacemakers, for they shall be called sons of God.
10“Blessed are those who are persecuted for righteousness' sake, for theirs is the
kingdom of heaven. 11“Blessed are you when others revile you and persecute you and
utter all kinds of evil against you falsely on my account. 12Rejoice and be glad, for your
reward is great in heaven, for so they persecuted the prophets who were before you.”
Amen.




# ពីមនុស្សខ្វះប្រាជ្ញា មកជាមនុស្សមានប្រាជ្ញា

កញ្ញា រិល សាវង្ស ជាសិស្សវិទ្យាល័យថ្នាក់ទី ១២ ស្នាក់នៅ ភូមិវត្តហ្លួង ឃុំលលកស ខេត្តពោធិ៍សាត់ បានធ្វើទីបន្ទាល់ថា៖ កាលពីមុនពេល ដែលនាងទទួលជឿព្រះយេស៊ូវគ្រីស្ទ នាងមិនសូវជាមានប្រាជ្ញាវៃឆ្លាតក្នុងការរៀនសូត្រឡើយ ដោយហេតុនេះហើយ បានជានាងគិតតែពីដើរលេងជាមួយភឿនកន មិនសូវជាខ្វល់ខ្វាយពីការរៀនសូត្រឡើយ។ ស្រាប់តែមានថ្ងៃមួយ ការប្រឡងឆមាសលើកទី១ បានឈានមកដល់ កញ្ញា សាវង្ស មិនចេះអ្វីទាល់តែសោះ បានជាដូច្នេះហើយនាងទទួលបានពិន្ទុមិនល្អឡើយ ធ្វើឲ្យនាងមានសេចក្ដីខ្មាសអៀនគេជាខ្លាំងណាស់ មិត្តភក្ត្ររបស់នាងនៅក្នុងថ្នាក់រៀនសើចចម្អកដាក់នាង ថានាងអន់ មិនមានប្រាជ្ញាឈ្លាសវៃដូចជាគេឡើយ។ ដំណឹងនេះក៏បានលេចឮទៅដល់ឪពុកម្ដាយនាង តាមរយៈអ្នកគ្រូប្រចាំថ្នាក់របស់នាង គាត់បានទៅលេងផ្ទះរបស់នាង រួមទាំងឪពុកម្ដាយមិត្តភក្ត្ររបស់នាង ដែលរស់នៅក្នុងភូមិជាមួយផងដែរ ពួកគាត់បានប្រាប់ពីលទ្ធផលរៀនសូត្ររបស់នាងទៅឪពុកម្ដាយនាង។ ពេលនោះឪពុកម្ដាយរបស់នាង បានស្ដីបន្ទោសដល់

នាងជាខ្លាំង បណ្ដាលឲ្យនាងមានសេចក្ដីតូចចិត្តជាពន់ប្រមាណ នាងបានទៅអង្គុយយំតែម្នាក់ឯង នៅក្បែរផ្ទឹមចម្បើងមួយ ដែលស្ថិតនៅមិនឆ្ងាយពីផ្ទះរបស់នាងឡើយ។

មានថ្ងៃមួយមានអ្នកគ្រូម្នាក់ ដែលជាគ្រូផ្សាយដំណឹងល្អអំពីព្រះយេស៊ូវ បានធ្វើដំណើរមកលេងផ្ទះរបស់នាង គាត់បានជួបនឹងឪពុកម្ដាយរបស់នាង ព្រមទាំងនាងផងដែរ។ អ្នកគ្រូនោះបានសួរសុខទុក្ខពីជីវភាពរស់នៅរបស់ក្រុមគ្រួសាររបស់នាង ពីការលំបាកដែលកំពុងតែជួបប្រទះក្នុងជីវិតរស់នៅប្រចាំថ្ងៃ ស្រាប់តែពេលនោះ ឪពុកម្ដាយរបស់នាងបាននិយាយប្រាប់ពីអាថ៌កំបាំងរបស់នាងទៅអ្នកគ្រូម្នាក់នោះ អំពីការដែលនាងមិនសូវមានប្រាជ្ញាឈ្លាសវៃក្នុងការរៀនសូត្រ មិនថាតើនាងអាចមានលទ្ធភាពក្នុងការសញ្ញាបត្រទុតិយភូមិ នាចុងឆ្នាំសិក្សានេះជាប់ដែរអត់។ ចំណែក នាង សាវង្ស មានសេចក្ដីខ្មាសអៀននឹងអ្នកគ្រូផ្សាយដំណឹងល្អអំពីព្រះយេស៊ូវនោះ ជាខ្លាំង ព្រោះថាឪពុកម្ដាយនាងមិនគួរណានឹងយករឿងអាថ៌កំបាំងរបស់នាងទៅប្រាប់ដល់អ្នកគ្រូម្នាក់នោះឡើយ។

ចំណែកឯអ្នកគ្រូផ្សាយដំណឹងល្អអំពីព្រះយេស៊ូវម្នាក់នោះ ញញឹមហាក់បីដូចជាគ្មានកង្វល់អ្វីសោះឡើយ តែគាត់បែរជានិយាយប្រាប់ឪពុកម្ដាយនាង និងនាង សាវង្ស ថា៖ កុំព្រួយបារម្ភអ្វីឡើយ ដ្បិតមានព្រះអង្គសង្គ្រោះមួយអង្គបានយាងមកផែនដីយើងនេះ ព្រះអង្គនោះគឺជាព្រះអង្គសង្គ្រោះដល់មនុស្សយើងឲ្យរួចពីបាប ព្រះអង្គអាចជួយសង្គ្រោះយើងទាំងអស់គ្នាឲ្យរួចពីបាបបាន។ ព្រះអង្គគឺជាព្រះយេស៊ូវគ្រីស្ទ អាចជួយឲ្យនាង សាវង្ស មានប្រាជ្ញាក្នុងការរៀនសូត្របាន ប្រសិនបើនាង សាវង្ស ស្ម័គ្រចិត្តទទួលយកព្រះអម្ចាស់យេស៊ូវគ្រីស្ទ ធ្វើជាព្រះអង្គសង្គ្រោះរបស់ខ្លួនផ្ទាល់ នោះសូមឲ្យនាងអធិស្ឋានទូលថ្វាយដល់ព្រះអង្គថានាងជាមនុស្សមានបាប សុខចិត្តដើរតាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយស្ដាប់បង្គាប់របស់ផងទ្រង់ ដើម្បីព្រះអង្គបានលាងសម្អាតអំពើបាបពីខ្លួននាង ដោយព្រះលោហិតរបស់ផងទ្រង់ ដែលខ្ចាយនៅលើឈើឆ្កាង។ មិនតែប៉ុណ្ណោះ ព្រះអម្ចាស់នឹងប្រទានព្រះពរតាមអ្វីដែលនាងចង់បានដូចជាប្រាជ្ញា ក្នុងការរៀនសូត្រជាដើម។ នៅពេលដែលនាង សាវង្ស បានឮពីដំណឹងល្អនោះរួចហើយភ្លាម និងដោយសារតែបំណងប្រាថ្នារបស់នាង ចង់បានប្រាជ្ញាឈ្លាសវៃក្នុងការរៀនសូត្រ ដើម្បីអាចនឹងប្រឡងសញ្ញាបត្រទុតិយភូមិជាប់ ដែលនឹងត្រូវប្រព្រឹត្តទៅនៅចុងឆ្នាំសិក្សាខាងមុខឆាប់ៗនេះហើយ នាងក៏សម្រេចចិត្តទទួលយកព្រះអ

ម្ចាស់យេស៊ូវគ្រីស្ទ ធ្វើជាព្រះអង្គសង្គ្រោះក្នុងជីវិតរបស់នាង ដើម្បីឲ្យព្រអង្គទ្រង់ជួយដល់នាង ដោយប្រទានពរដល់នាងឲ្យមានប្រាជ្ញាឈ្លាសវៃ ក្នុងការសិក្សារៀនសូត្រ ចងចាំ និងគ្រប់ទាំងមេរៀនដែលលោកគ្រូ អ្នកគ្រូ បង្ហាត់បង្រៀននៅសាលារៀន។

ចាប់ពីនោះមក ជាពិតណាស់ គ្រាន់តែដួងចិត្តរបស់នាង សាវង្ស បានផ្លាស់ប្រែទទួលយកព្រះអម្ចាស់យេស៊ូវគ្រីស្ទ ធ្វើជាព្រះអង្គសង្គ្រោះសម្រាប់ជីវិតរបស់នាង នាងមានការផ្លាស់ប្រែពីការ ដែលចេះដើរលេងឥតប្រយោជន៍ មកជាការខិតខំប្រឹងសំភីរៀនសូត្រ ធ្វើឲ្យនាងអាចចេះចាំគ្រប់ទាំងមេរៀន ដែលលោកគ្រូ អ្នកគ្រូបង្ហាត់បង្រៀននៅសាលារៀន ព្រមទាំងចេះស្តាប់បង្គាប់ឪពុកម្តាយនាង ហើយនិងចេះជួយធ្វើការងារនៅផ្ទះជំនួសដៃឲ្យឪពុកម្តាយនាងទៀតផង។ ការនេះធ្វើឲ្យឪពុកម្តាយនាងមានការភ្ញាក់ផ្អើល និងមានងឿងឆ្ងល់ជាពន់ប្រមាណ តែពួកគាត់មិនមានចេញស្តីអ្វីទាល់តែសោះ ពួកគាត់ចេះតែកត់សម្គាល់នៅក្នុងចិត្តរបស់ពួកគាត់ទៅ។ គ្រប់ការទាំងអស់ ដែលនាង សាវង្ស មានការផ្លាស់ប្រែចិត្ត ដោយព្រោះថា នាងបានអធិស្ឋានជាប់ជាប្រចាំទៅព្រះអម្ចាស់យេស៊ូវគ្រីស្ទ ពីទុក្ខលំបាក និងកង្វះខាត និងតម្រូវការចាំបាច់ក្នុងជីវិតរបស់នាង។ តាមរយៈការអធិស្ឋានរបស់នាង ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានឆ្លើយតបមកនាង ដោយប្រទានពរដល់នាងឲ្យមានប្រាជ្ញាឈ្លាសវៃ ក្នុងការសិក្សារៀនសូត្រ ក៏ដូចជាគ្រប់ទាំងអស់សម្រាប់ជាទីបន្ទាល់អំពីព្រះចេស្តា និងព្រះសិរីល្អរបស់ផងទ្រង់ ដល់អស់មនុស្សនៅក្នុងភូមិ និងសាលារៀន ដែលនាង សាវង្ស រស់នៅ និងសិក្សារៀនសូត្រ។ ជាពិសេសដល់ឪពុកម្តាយនាង និងក្រុមគ្រួសារទាំងមូលផងដែរ។ ជាលទ្ធផលដ៏ជាទីគាប់ចិត្ត និងគួរឲ្យសប្បាយរីករាយរកអ្វីមកប្រៀបផ្ទឹមពុំបាននោះ នាង សាវង្ស បានប្រឡងជាប់សញ្ញាបត្រទុតិយភូមិ និទ្ទេស B ពេលនោះហើយសបញ្ជាក់ថា ពិតជាមានព្រះយេស៊ូវគ្រីស្ទមែន ព្រះអង្គទ្រង់មានព្រះជន្មរស់នៅសព្វថ្ងៃនេះ ព្រះអង្គតែងតែយកព្រះទ័យទុកដាក់នឹងរាស្ត្ររបស់ផងទ្រង់ជានិច្ច ព្រះអង្គមិនដែលទតសម្លឹងមើលរំលងរាស្ត្ររបស់ទ្រង់ឡើយ។ ដូចដែលមានចែងក្នុងបទគម្ពីរ យ៉ាកុប ១:៥ ថា៖ □តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ□។

ចាប់តាំងពីថ្ងៃនោះមក គ្រប់ទាំងព្រះបន្ទូល ដែលនាង សាវង្ស បានអាន និងបន្តអានជារៀងរាល់ថ្ងៃ បានដុះឡើងចាក់ឫសស៊ីជម្រៅក្នុងដួងចិត្តរបស់នាង ធ្វើឲ្យនាងបន្តផ្សាយដំណឹងល្អនេះទៅឪពុកម្តាយនាង បងប្អូនរបស់នាង ព្រមទាំងអ្នកភូមិផងរបងជាមួយនឹងនាង ឲ្យទទួលជឿ ដល់ព្រះយេស៊ូវគ្រីស្ទ ដោយទទួលយកព្រះអម្ចាស់ធ្វើជាព្រះអង្គសង្គ្រោះក្នុងជីវិតផ្ទាល់ខ្លួនម្នាក់ៗ។ ព្រោះថា ព្រះអង្គគឺជាព្រះលើសទាំងព្រះ ជាព្រះដ៏មានព្រះជន្មរស់ ព្រះអង្គស្មោះត្រង់ សុចរិត និងពោរពេញទៅដោយសេចក្តីមេត្តាករុណាដល់យើងគ្រប់ៗគ្នា ព្រះអង្គមិនដែលបោះបង់ចោលយើងឡើយ ជានិច្ចជាកាលព្រះអង្គតែងតែមានព្រះហឫទ័យអាណិតស្រឡាញ់ដល់យើងគ្រប់ៗគ្នា ហើយថែមទាំងផ្តត់ផ្គង់ប្រទានឲ្យនូវអ្វីៗគ្រប់យ៉ាងដែលយើងទូលសូមនោះផងដែរ ដូចមានចែងក្នុងបទគម្ពីរ លោកុប្បត្តិ ២២:១៤ ថា៖ □អ័ប្រាហាំហៅកន្លែងនោះថា □យេហូវ៉ា-យីរេ□ ដូចជាគេក៏និយាយដរាបដល់សព្វថ្ងៃនេះដែរថា នៅភ្នំនៃព្រះយេហូវ៉ា គឺទ្រង់នឹងផ្គត់ផ្គង់ឲ្យ។□។ ក៏ដូចគ្នានេះដែរ ព្រះយេស៊ូវគ្រីស្ទ ក៏បានមានព្រះបន្ទូលប្រាប់នៅក្នុងបទគម្ពីរ ម៉ាថាយ ៧:៧-៨ ថា៖ □[៧]ចូរសូម នោះតែងនឹងឲ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក [៨]ដ្បិតអស់អ្នកណាដែលសូម នោះរមែងបាន អ្នកណាដែលរកនោះរមែងឃើញ ហើយនឹងបើកឲ្យអ្នកណាដែលគោះដែរ□។ អាមែន។

## *From A Foolish To A Wise*

Miss. Rel Savong, a 12th grade high school student living in Wat Luong village, Lolok Sor commune, Pursat province, testified: "Before her belief in Jesus Christ, she had no wisdom to learn, so she was only interested in walking with her friends not to worry about learning. One day, the first semester exam came down to Miss Savong, so she got a bad score, making her ashamed, her friends in class laugh at her, telling her she was not as smart as them. The news was also told to her parents through her classmaster, who visited her home, including her parents' classmates, who lived in the same village, with the result of telling about her studies. Her parents blamed her so much that she was so upset that she went alone to a pile of hay, which is not far from her home.

One day, a teacher who was an evangelist about Jesus visited her home, met her parents, and her. The teacher asked for her family's life with the difficulties that

were encountered in daily life, when her parents told that teacher about her lack of academic ability, whether she was able to pass a diploma at the end of the school year or not. She was shamed by the evangelistic teachers of Jesus because her parents should never tell her secret to that teacher.

And the evangelical teacher of Jesus, with a smile, seemed to have no worries, but she told her parents: "Do not be alarmed, for a Savior has come to the earth; He is the Savior of our sins, and He is able to save us from all sin. He is Jesus Christ can help Miss Savong to be wise for learning if she voluntarily accepts the Lord Jesus Christ as her Savior, so let she prays to Him that she is a sinner who is willing to follow the Lord Jesus Christ in obedience to Him in order to wash her sins by the blood of Jesus Christ on the cross. Not only the Lord will bless whatever she wants, like wisdom to learn. As soon as she heard the Gospel, and because her desire for wisdom to learn to be able to pass the high school diploma, which will be held at the end of the academic year, she decides to accept the Lord Jesus Christ as her Savior in her life so that He could help her and bless her in studies, memorization for every lesson she teaches at school.

Since then, of course, just the hearts of Miss Savong was changed to accept the Lord Jesus Christ as Savior in her life, she was transformed from a walk in vain to have the efforts to learn her lessons. She can remember all lessons that teachers were teaching at schools as well as she was obedient to her parents and to render working at home for her parents. This makes her parents surprised and wondered, but they do not say anything, but they take notice in their hearts. All that she had to repent because of she prayed constantly to the Lord Jesus Christ and told Him about her hardships and shortcomings, and necessities of her life. Through her prayer, the Lord Jesus Christ responded by blessing her to be wise in learning, as well as to all, as a testimony of His power and glory to all the people in the village and the school where she lived and studied. Especially to her parents and the whole family. As a satisfying and delightful result, Miss Savong passed a diploma in High School B degree and then proved that to be true Jesus Christ, and He is alive today. He always takes care for His people. He does not look beyond His people. As stated in James 1: 5, “If any of you lacks wisdom, let him ask God, who gives generously to all without reproach, and it will be given him.”

Since that day, every Word she has read and continues to read daily grows deeply rooted in her heart, making her continue to preach the Gospel to her parents, her brothers and sisters, and her fellow villagers to accept Jesus Christ as the Lord as the Savior in each individual's life. Because He is God of gods, the living God, faithful God, righteous, and merciful God to all of us, He has never forsaken us. He always

shows His tender affection for us all, and He supplies all that we ask, as we read in Genesis 22:14: “place, “The LORD will provide”; as it is said to this day, “On the mount of the LORD it shall be provided.” Likewise, Jesus Christ said in Matthew 7: 7-8: “[7]“Ask, and it will be given to you; seek, and you will find; knock, and it will be opened to you. [8]For everyone who asks receives, and the one who seeks finds, and to the one who knocks it will be opened.” Amen.